ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

KINGDOM OF CAMBODIA

Nation - Religion - King

ក្រសួងពាណិជ្ជកម្ម

Ministry of Commerce

No. ១៦៤ MOC / M 2004

# ប្រកាស

## ស្តីពីការបង្កើតគណៈកម្មការរៀបចំការបោះឆ្នោតជ្រើសរើស សមាជិកជ្រើសតាំង នៃសភាពាណិជ្ជកម្មខេត្ត-ក្រុង

*****

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកប/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានឃើញព្រះរាជក្រមលេខ នស/រកស/០៦៩៥/០៣ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសភាពាណិជ្ជកម្ម

-បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងពាណិជ្ជកម្ម

-បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីរបៀបរបប និងការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម

-បានឃើញអនុក្រឹត្យលេខ ២២ អនក្រ.កប. ២៣ អនក្រ.បក. ២៤ អនក្រ.បក . ២៥ អនក្រ.បក. ២៦ អនក្រ.បក និង ២៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើតសភាពាណិជ្ជកម្មខេត្តកំពង់ចាម, បាត់ដំបង, បន្ទាយមានជ័យ, កោះកុង, សៀមរាប និងក្រុងសីហនុ

-យោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សំរេច

**ប្រការ ១:** បង្កើតគណៈកម្មាការ រៀបចំការបោះឆ្នោតជ្រើសរើស សមាជិកជ្រើសតាំង នៃសភាពាណិជ្ជកម្មខេត្ត-ក្រុង ដែលមានសមាភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម **ម៉ៅ ថូរ៉ា** | អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | ជាប្រធាន |
| ២-អ្នកឧកញ៉ា **សុខ គង់** | ប្រធានសភាពាណិជ្ជកម្មរាជធានីភ្នំពេញ | ជាអនុប្រធាន |

៣-លោក **សម សម្បត្តិ** អគ្គនាយករងបច្ចេកទេស នៃក្រសួងពាណិជ្ជកម្ម ជាសមាជិក

៤-លោក **ឡោក់ នក** ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស នៃក្រសួងពាណិជ្ជកម្ម ជាសមាជិក

៥-លោក ឧកញ៉ា **ណារា សុធី** អគ្គនាយកសភាពាណិជ្ជកម្មរាជធានីភ្នំពេញ ជាសមាជិក

៦-លោក លោកស្រី ប្រធានមន្ទីរពាណិជ្ជកម្មខេត្ត-ក្រុង ជាសមាជិក

៧-លោក **ហ៊ុម ហ៊ាន** អនុប្រធាននាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស នៃក្រសួងពាណិជ្ជកម្ម ជាលេខាធិការ

៨-លោក **ធន ទិវះ** អនុប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេសនៃក្រសួងពាណិជ្ជកម្ម ជាលេខាធិការ

**ប្រការ ២:** គណកម្មាការនេះ មានភារកិច្ចធ្វើសហប្រតិបត្តិការ ជាមួយគណកម្មាការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម នៅតាមខេត្ត-ក្រុងនីមួយៗ ក្នុងការចុះបញ្ជីអ្នកបោះឆ្នោត ចុះបញ្ជីបេក្ខជនឈរឈ្មោះ និងរៀបចំការបោះឆ្នោតទៅតាមខ្លឹមសារទាំងឡាយ ដែលបានចែងអំពីភារកិច្ចរបស់គណកម្មាការនៅក្នុងជំពូក២ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃ ១៧ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីរបៀបរបប និងការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម ។

**ប្រការ ៣:** បទបញ្ញត្តិទាំងឡាយ ដែលមានន័យផ្ទុយពីប្រការនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៤:** អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស នាយិកាខុទ្ទកាល័យ សភាពាណិជ្ជកម្មរាជធានីភ្នំពេញ និងសាមីខ្លួន ត្រូវអនុវត្តតាមប្រកាសនេះ អោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០០៤

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម_ប្រសិទ្ធ**

**កន្លែងទទួល:**

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង

-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ

-សាលាក្រុងភ្នំពេញ

-ដូចប្រការ ៤ " ដើម្បីអនុវត្ត"

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ